ស្ថានទូតអូស្ត្រាលី ភ្នំពេញ

# <u>សេចក្តីប្រកាសព័ត៌មាន</u>

ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២២

## វេទិកាអ្នកដឹកនាំជាស្ត្រី អាស៊ាន-អូស្ត្រាលី៖
## ការលើកកម្ពស់សហគ្រិនភាពស្ត្រី ឆ្ពោះទៅរកកំណើនសេដ្ឋកិច្ចក្នុងតំបន់

កាលពីថ្ងៃទី១១ និង១២ ខែធ្នូ ឆ្នាំ ២០២២ លោកជំទាវ ចន្ទ សូរិយ៍ រដ្ឋលេខាធិការ ជាតំណាងមកពីក្រសួងកិច្ចការនារីកម្ពុជា និង លោកជំទាវ គ្រីស្ទីន ខ្លក ឯកអគ្គរាជទូតអូស្ត្រាលីទទួលបន្ទុកកិច្ចការស្ត្រី និងកុមារី ព្រមទាំង ឯកឧត្តម ផាប្លូ កាង ឯកអគ្គរាជទូតអូស្ត្រាលីប្រចាំកម្ពុជា បានសហការរៀបចំកម្មវិធី **"វេទិកាអ្នកដឹកនាំជាស្ត្រី អាស៊ាន-អូស្ត្រាលី៖ ការលើកកម្ពស់សហគ្រិនភាពជាស្ត្រី ឆ្ពោះទៅរកកំណើនសេដ្ឋកិច្ចក្នុងតំបន់"**។ វេទិកានេះជាផ្នែកមួយនៃកិច្ចប្រជុំកំពូលអ្នកដឹកនាំស្ត្រីអាស៊ានលើកទី២ ដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះប្រកបដោយជោគជ័យ កាលពីថ្ងៃទី១២ ខែតុលា ឆ្នាំ២០២២។

អូស្ត្រាលីមានមោទនភាពដែលបានក្លាយជាដៃគូសន្ទនាអាស៊ានដ៏សំខាន់ ក្នុងការគាំទ្រកម្ពុជាធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំកំពូលអ្នកដឹកនាំស្ត្រី ដែលផ្តោតលើបញ្ហាសំខាន់នៃការពង្រីកសហគ្រិនភាពរបស់ស្ត្រីនៅក្នុងអាស៊ាន។ អ្នកដឹកនាំអាស៊ាន បានជំរុញការសម្រេចការអនុវត្ត "សេចក្តីថ្លែងការណ៍ស្តីពីការកសាងអនាគតប្រកបដោយចីរភាព បរិយាបន្ន និងកាន់តែរឹងមាំ៖ បំផុសសហគ្រិនភាពរបស់ស្ត្រីនៅក្នុងអាស៊ាន" នៅក្នុងកិច្ចប្រជុំកំពូលអាស៊ានលើកទី៤១ នៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២២ កន្លងមក។

ដើម្បីបន្តលទ្ធផលនៃកិច្ចប្រជុំកំពូល និងសេចក្តីថ្លែងការណ៍ កម្ពុជា និងអូស្ត្រាលីបានសហការធ្វើជាម្ចាស់ផ្ទះនៃវេទិកាអ្នកដឹកនាំជាស្ត្រី អាស៊ាន-អូស្ត្រាលី នៅថ្ងៃទី១១ និង១២ ខែធ្នូ ឆ្នាំ ២០២២ ដែលបាននាំយកសហគ្រិនជាស្ត្រីចំនួន ២៦នាក់ មកពីអូស្ត្រាលី និងគ្រប់ប្រទេសជាសមាជិកអាស៊ាន។ ក្នុងរយៈពេលពីរថ្ងៃនេះ សហគ្រិនអាស៊ាន និងអូស្ត្រាលីបានពិភាក្សាអំពីបញ្ហាប្រឈមនានា និងចែករំលែកមេរៀនដែលទាក់ទងនឹងការក្លាយជាសហគ្រិននៅក្នុងតំបន់។ វេទិកានេះបានបញ្ចប់ក្នុងសម័យប្រជុំពេញអង្គដែលមានអ្នកចូលរួមជាង ១០០នាក់ មកពីស្ថាប័នរដ្ឋាភិបាល ធុរកិច្ច និងស្ថានទូតនានានៅកម្ពុជា។

លោកជំទាវ រដ្ឋលេខាធិការ ចន្ទ សូរិយ៍ និងលោកជំទាវ ឯកអគ្គរាជទូត គ្រីស្ទីន ខ្លក បានទទួលស្គាល់អំពីតម្លៃនៃការរៀនសូត្រពីសហគ្រិនស្ត្រីអំពីខ្លួនរបស់គាត់ ដោយសង្ឃឹមថានឹងជួយការលើកកម្ពស់សហគ្រិនភាពជាស្ត្រី។ លទ្ធផលដែលទទួលបានពីវេទិកានេះនឹងរួមចំណែកដល់សកម្មភាពជាក់ស្តែងឆ្ពោះទៅរកការអនុវត្តសេចក្តីថ្លែងការណ៍ ស្តីពី "ការកសាងអនាគតប្រកបដោយចីរភាព បរិយាបន្ន និងកាន់តែរឹងមាំ៖ បំផុសសហគ្រិនភាពរបស់ស្ត្រីនៅក្នុងអាស៊ាន"។

លោកជំទាវ ឯកអគ្គរាជទូត គ្រីស្ទីន ខ្លក ក៏ឆ្លៀតឱកាសទៅទស្សនាមជ្ឈមណ្ឌលជាតិគ្រប់គ្រងកងកម្លាំងរក្សាសន្តិភាព ដើម្បីនិយាយទៅកាន់កងកម្លាំងរក្សាសន្តិភាពជាស្ត្រី និងទៅទស្សនាអាជីវកម្មដែលគ្រប់គ្រងដោយស្ត្រីកម្ពុជា ដែលគាំទ្រដោយកម្មវិធីអភិវឌ្ឍន៍អូស្ត្រាលី។ ក្នុងអំឡុងពេលមកបំពេញទស្សនកិច្ចនៅកម្ពុជា លោកជំទាវអាចស្វែងយល់អំពីការវិនិយោគរយៈពេលវែងរបស់អូស្ត្រាលី ក្នុងកម្មវិធីទាក់ទងនឹងយេនឌ័រនៅកម្ពុជា រួមទាំងការប្រឆាំងអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងធានាថាស្ត្រី និងជនងាយរងគ្រោះអាចចូលរួម និងទទួលបានអត្ថប្រយោជន៍ស្មើគ្នាពីសេដ្ឋកិច្ច។

ខែធ្នូ ឆ្នាំ២០២២ ក៏ជាខែចុងក្រោយនៃខួបទី៧០ឆ្នាំ នៃទំនាក់ទំនងទ្វេភាគីកម្ពុជា-អូស្ត្រាលីផងដែរ។ វេទិកាអាស៊ាន-អូស្ត្រាលីនេះ ឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តយ៉ាងខ្ជាប់ខ្ជួនរបស់កម្ពុជា និងអូស្ត្រាលី ចំពោះការពង្រឹងអំណាចសេដ្ឋកិច្ចរបស់ស្ត្រី។ កម្ពុជា និងអូស្ត្រាលី ទន្ទឹងរង់ចាំធ្វើការរួមគ្នានៅឆ្នាំខាងមុខទៀតតាមរយៈអាស៊ាន និងទំនាក់ទំនងទ្វេភាគី ដើម្បីបង្កើនសមភាពសេដ្ឋកិច្ចរបស់ស្ត្រី។

**ទំនាក់ទំនងព័ត៌មាន៖**

ស្ថានទូតអូស្ត្រាលី Media.Cambodia@dfat.gov.au

ក្រសួងកិច្ចការនារីកម្ពុជា mowa.edd@gmail.com